សំណួរ ចម្លើយ
ស្តីពី
ការយល់ដឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨

<u>សំណួរ១</u>: ដូចម្តេចដែលហៅថាការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៨?

<u>ចម្លើយ:</u> ដែលហៅថាការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៨គឺ ៖

ក. ការពិនិត្យបញ្ជីឈ្មោះ

- ប្រជាពលរដ្ឋដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៧ ត្រូវទៅពិនិត្យមើលឈ្មោះ និងទិន្នន័យនៅលើបញ្ជីបោះឆ្នោតចុងក្រោយ ដើម្បីឱ្យប្រាកដថាឈ្មោះ និងទិន្នន័យរបស់ ខ្លួនពិតជាត្រឹមត្រូវ
- ការកែតម្រូវឈ្មោះ និងទិន្នន័យអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៧ ឬការសុំប្តូរ ការិយាល័យបោះឆ្នោតដែលស្ថិតនៅក្នុងឃុំ សង្កាត់ដដែល
- ការលុបឈ្មោះអ្នកបោះឆ្នោតដែលទទួលមរណភាព ដែលត្រូវបានដកហូតជាបណ្តោះ អាសន្ននូវសិទ្ធិបោះឆ្នោត ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង។

ខ. ការចុះឈ្មោះបោះឆ្នោត

- ចុះឈ្មោះប្រជាពលរដ្ឋដែលទើបគ្រប់អាយុ១៨ឆ្នាំ គិតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ (កើតមុន ឬត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០១)
- ចុះឈ្មោះប្រជាពលរដ្ឋដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុន
- ចុះឈ្មោះប្រជាពលរដ្ឋដែលទើបបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មីមករស់នៅក្នុងឃុំ សង្កាត់។

<u>សំណួរ២</u>: យ៉ាងដូចម្តេចដែលហៅថាបញ្ជីបោះឆ្នោតចុងក្រោយ?

<u>ចម្លើយ:</u> បញ្ជីបោះឆ្នោតចុងក្រោយ គឺជាបញ្ជីបោះឆ្នោតផ្លូវការដែល គ.ជ.ប បានផ្តល់សុពលភាពចុងក្រោយនៅ ឆ្នាំ២០១៧។

<u>សំណួរ៣</u>: ហេតុអ្វីត្រូវពិនិត្យមើលការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ ឆ្នាំ២០១៧?

<u>ចម្លើយ:</u> ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៧ ត្រូវអញ្ជើញទៅពិនិត្យមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ឆ្នាំ២០១៧ ដែលបានបិទផ្សាយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ នៅសាលាឃុំ សង្កាត់ និងនៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ ដើម្បីឱ្យប្រាកដថាឈ្មោះរបស់ខ្លួនមាននៅក្នុងបញ្ជីបោះឆ្នោត។ ករណីពិនិត្យឃើញឈ្មោះរបស់ខ្លួនមានខុសអក្ខរាវិរុទ្ធ ឬខុសទិន្នន័យ សាមីខ្លួនត្រូវទៅជួបក្រុមចុះឈ្មោះបោះឆ្នោតដើម្បីស្នើសុំកែតម្រូវឱ្យ ត្រឹមត្រូវតាមអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួនវិញ។

<u>សំណួរ៤</u>: តើប្រជាពលរដ្ឋត្រូវទៅចុះឈ្មោះបោះឆ្នោតនៅកន្លែងណា?

<u>ចម្លើយ</u>: ប្រជាពលរដ្ឋត្រូវទៅចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំ សង្កាត់ និងនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនកំពុង រស់នៅ។

<u>សំណួរ៥</u>: តើការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅសាលាឃុំ សង្កាត់ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅពេលណា និងបញ្ចប់នៅ ពេលណា?

<u>ចម្លើយ</u>: ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំ សង្កាត់ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ នៅពេលចាប់ផ្តើម និងពេលបញ្ចប់ដោយប្រើរយៈពេលប្រមាណពាក់កណ្តាលនៃរយៈពេលចុះឈ្មោះបោះឆ្នោតសរុប។

<u>សំណួរ៦</u>: តើការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅពេលណា?

<u>ចម្លើយ</u>: ការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅតាមភូមិមួយចំនួន ក្រៅពីសាលាឃុំ សង្កាត់ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតដោយប្រើពេលវេលាសរុបមិនឱ្យលើសពីមួយភាគពីរនៃរយៈពេលរួមដែលបានកំណត់ (មានរយៈពេល ០៩ ថ្ងៃចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៨)។

<u>សំណួរ៧</u>: តើក្នុងមួយសប្តាហ៍ការិយាល័យចុះឈ្មោះបោះឆ្នោត បើកបម្រើការចុះឈ្មោះបោះឆ្នោតប៉ុន្មានថ្ងៃ និងពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

<u>ចម្លើយ</u>: ការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការជារៀងរាល់ថ្ងៃគិតទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ ពេលព្រឹកចាប់ពីម៉ោង ៧:០០ ដល់ម៉ោង ១១:៣០ នាទីថ្ងៃត្រង់ និងពេលរសៀលចាប់ពីម៉ោង ២:០០ ដល់ម៉ោង ៥:៣០ នាទីល្ងាច។ ក្នុងករណីមានវត្តមានអ្នកសុំចុះឈ្មោះបោះឆ្នោតបន្តក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមចុះឈ្មោះបោះឆ្នោត អាចបន្ថែមម៉ោងនៃការចុះឈ្មោះបោះឆ្នោតតាមការជាក់ស្តែង។

<u>សំណួរ៨</u>: តើការិយាល័យបោះឆ្នោតនីមួយៗត្រូវមានប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោតយ៉ាងច្រើនប៉ុន្មាននាក់?

<u>ចម្លើយ</u>: ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោតយ៉ាងច្រើន ៧៥០ (ប្រាំពីររយហាសិប) នាក់។

<u>សំណួរ៩</u>: តើបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត បិទផ្សាយនៅកន្លែងណា និងនៅពេលណា?

ចម្លើយ: បញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោតមានបិទផ្សាយជាសាធារណៈ នៅសាលាឃុំ សង្កាត់ និងនៅទីតាំងមួយ ចំនួនក្នុងឃុំ សង្កាត់ យ៉ាងតិច១០ ថ្ងៃមុនពេលចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត គឺថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ និងនៅតាមគេហទំព័រ គ.ជ.ប ដែលមានអាសយដ្ឋាន www.voterlist.org.kh និង www.necelect.org.kh ។

<u>សំណួរ១០</u>: តើមានទោសកម្រិតណាចំពោះជនដែលចេតនាយកអាវុធ ជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត?

ចម្លើយ: មាត្រា១៤៦ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា : ត្រូវជាកពិន័យជាប្រាក់ពី ៥,000,000រៀល ទៅ ១0,000,000រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយ គ.ជ.ប ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

<u>សំណួរ១១</u>: តើប្រជាពលរដ្ឋអាចចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតមុនពេល ឬក្រោយពេល បើក ឬបិទការិយាល័យបានដែរឬទេ?

ចម្លើយ: ហាមជនគ្រប់រូបចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត មុនពេលការិយាល័យចាប់ផ្តើមធ្វើការ ឬក្រោយពេលការិយាល័យបិទទ្វារដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។

<u>សំណួរ១២</u>: តើសកម្មភាពណាខ្លះ ដែលត្រូវហាមឃាត់នៅបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត?

ចម្លើយ: សកម្មភាពដែលត្រូវហាមឃាត់មានដូចខាងក្រោម ៖

- ការស្លៀកពាក់ឯកសណ្ឋាន ឬការបិទផ្សាយស្លាកសញ្ញា ឬការនិយាយដែលមានការពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ
- ការបង្ហាញការគាំទ្រ ឬការប្រឆាំងចំពោះគណបក្សនយោបាយណាមួយ
- ការរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត
- ការបង្កការអុកឡុក ឬការរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

<u>សំណួរ១៣</u>: ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត តើប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ?

ចម្លើយ: ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោតប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ

- មានអាយុ ១៨ ឆ្នាំឡើងទៅគិតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ (កើតមុន ឬត្រឹមថ្ងៃទី០១ ខែ មករា ឆ្នាំ២០០១)
- មានលំនៅហាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត
- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

<u>សំណួរ១៤</u>: ដើម្បីចុះឈ្មោះបោះឆ្នោត តើប្រជាពលរដ្ឋទាំង២ភេទ ត្រូវបំពេញលក្ខខណ្ឌដូចម្តេចខ្លះ?

<u>ចម្លើយ:</u> ដើម្បីចុះឈ្មោះបោះឆ្នោតប្រជាពលរដ្ឋទាំង២ភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវបង្ហាញខ្លួន និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត នៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោតដែលទទួលបន្ទុកជាមន្ត្រីចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ដែលខ្លួនកំពុងរស់នៅ
- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ឆ្នាំឡើងទៅគិតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ (កើតមុន ឬត្រឹមថ្ងៃទី០១ ខែ មករា ឆ្នាំ២០០១)
- មានលំនៅហាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត
- មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់។

<u>សំណួរ១៥</u>: យ៉ាងដូចម្តេចដែលហៅថាលំនៅហាន?

<u>ចម្លើយ:</u> លំនៅហាន គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ។

<u>សំណួរ១៦</u>: ប្រសិនបើទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ តើត្រូវធ្វើដូចម្តេច?

<u>ចម្លើយ:</u> ក្នុងករណីដែលកន្លែង ដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅហាន។ ទីសំណាក់សំដៅលើទីហាន ដែលបុគ្គលម្នាក់ស្នាក់អាស្រ័យនៅ ឬអាស្រ័យនៅជាក់ស្តែងក្នុងរយៈពេលជាកំណត់ណាមួយ។

<u>សំណួរ១៧</u>: តើប្រជាពលរដ្ឋដែលកំពុងស្នាក់នៅក្នុងឃុំ សង្កាត់ណាមួយ សុទ្ធតែអាចសុំចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ នោះបានដែរឬទេ?

<u>ចម្លើយ:</u> ប្រជាពលរដ្ឋ កម្មករ សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល នាយ ឬពលនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ និងបព្វជិត សាសនា ដែលកំពុងស្នាក់នៅក្នុងឃុំ សង្កាត់

ណាមួយ សុទ្ធតែអាចសុំចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់នោះបានទាំងអស់ ប្រសិនបើពួកគាត់បំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីចុះឈ្មោះបោះឆ្នោត។

<u>សំណួរ១៨</u>: ប្រជាពលរដ្ឋម្នាក់ៗ អាចមានឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយបានដែរឬទេ?

<u>ចម្លើយ:</u> ប្រជាពលរដ្ឋម្នាក់ៗ ត្រូវមានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់។

<u>សំណួរ១៩</u>: ប្រជាពលរដ្ឋដែលមានលំនៅឋាន ឬ/និងទីសំណាក់ច្រើនជាងមួយកន្លែង តើត្រូវចុះឈ្មោះបោះឆ្នោតយ៉ាងដូចម្តេច?

<u>ចម្លើយ:</u> ប្រជាពលរដ្ឋដែលមានលំនៅឋាន ឬ/និងទីសំណាក់ច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសយកកន្លែងតែមួយគត់ ដែលជាទីតាំងនៃជីវភាពរស់នៅជាក់ស្តែងរបស់បុគ្គលនោះ ដើម្បីចុះឈ្មោះបោះឆ្នោត។

<u>សំណួរ២០</u>: តើប្រជាពលរដ្ឋអាចឲ្យគេទៅចុះឈ្មោះបោះឆ្នោតជំនួសគាត់បានដែរឬទេ?

<u>ចម្លើយ:</u> ប្រជាពលរដ្ឋត្រូវបង្ហាញខ្លួនដោយផ្ទាល់ និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត នៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោតទទួលបន្ទុកជាមន្ត្រីចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅ។

<u>សំណួរ២១</u>: តើមានការសម្រួលសណ្តាប់ធ្នាប់យ៉ាងណានៅការិយាល័យចុះឈ្មោះបោះឆ្នោត?

<u>ចម្លើយ:</u> មន្ត្រីសណ្តាប់ធ្នាប់ និងរៀបចំឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោតឈរបន្តកន្ទុយគ្នានៅត្រង់មាត់ទ្វារចូលនៃការិយាល័យចុះឈ្មោះបោះឆ្នោត ហើយអនុញ្ញាតឲ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្តង ០៣នាក់។ ដោយឡែកព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនមានពិការភាព ត្រូវបានផ្តល់អាទិភាព។

<u>សំណួរ២២</u>: នៅពេលទៅចុះឈ្មោះបោះឆ្នោត តើប្រជាពលរដ្ឋត្រូវប្រើឯកសារអ្វីខ្លះ?

<u>ចម្លើយ:</u> ប្រជាពលរដ្ឋត្រូវប្រើឯកសារ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ប្រភេទទី១ ឬប្រភេទទី២ ឬប្រភេទទី៣)
- ឬ ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត។

<u>សំណួរ២៣</u>: ប្រជាពលរដ្ឋមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) រួចហើយ ប៉ុន្តែអាសយដ្ឋានលំនៅឋានក្នុង (អ.ខ) ខុសពីអាសយដ្ឋានលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត តើគាត់ត្រូវមានឯកសារអ្វីបន្ថែមទៀតដើម្បីយកទៅចុះឈ្មោះបោះឆ្នោត?

ចម្លើយ: ដើម្បីចុះឈ្មោះបោះឆ្នោតបាន គាត់ត្រូវមានឯកសារបន្ថែមដូចខាងក្រោម៖

ក- ប្រសិនបើគាត់មានសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើម ដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុង ឃុំ សង្កាត់ គាត់ត្រូវទៅជួបក្រុមចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោតដើម្បីសុំចុះឈ្មោះបោះឆ្នោត។

ខ- ប្រសិនបើគាត់គ្មានឯកសារដូចបញ្ជាក់ក្នុងចំណុច "ក" ខាងលើនេះទេគាត់ត្រូវទៅបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខមេឃុំ ចៅសង្កាត់ ដោយនាំទៅជាមួយនូវ "អ.ខ" និងសាក្សីមួយ រូបដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាមួយដើម្បីស្នើសុំលិខិតបញ្ជាក់ទីលំនៅ។ ប្រសិនបើទទួលបានលិខិតនេះក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត សាមីខ្លួនត្រូវទៅជួបក្រុមចុះឈ្មោះបោះឆ្នោត ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

<u>សំណួរ២៤</u>: ប្រជាពលរដ្ឋគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬមានហើយតែបាត់ ឬខូច តើត្រូវធ្វើដូចម្តេច ដើម្បីបានចុះឈ្មោះបោះឆ្នោត?

ចម្លើយ: សាមីខ្លួនត្រូវមកបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ ដើម្បីសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតដោយនាំមកនូវ ៖

- សំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រ បញ្ជាក់កំណើតច្បាប់ដើម ឬឯកសារផ្សេងៗទៀតដែលអាចបញ្ជាក់ពីសញ្ជាតិខ្មែរបាន។
- សាក្សី២រូបដែលមានសិទ្ធិបោះឆ្នោត មានលំនៅហាន ឬទីសំណាក់ពិតប្រាកដក្នុងឃុំ សង្កាត់ ជាមួយ។
- រូបថតទំហំ ៣x៤ ចំនួន២សន្លឹក។ បើសាមីខ្លួនបានទទួលឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត សាមីខ្លួនត្រូវត្រឡប់មកជួបក្រុមចុះឈ្មោះបោះឆ្នោតវិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

<u>សំណួរ២៥</u>: ប្រជាពលរដ្ឋធ្លាប់បានចុះឈ្មោះរួចហើយក្នុង តែបានប្តូរលំនៅហានទៅនៅភូមិផ្សេងក្នុងឃុំ សង្កាត់ ដដែល គាត់ចង់ប្តូរការិយាល័យបោះឆ្នោតតើត្រូវធ្វើដូចម្តេច?

ចម្លើយ: ក្នុងករណីនេះសាមីខ្លួនត្រូវទៅជួបក្រុមចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត ដោយយកទៅជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងឯកសារភស្តុតាងដែលបញ្ជាក់ទីលំនៅថ្មីនៅ ក្នុងឃុំ សង្កាត់ដូចជាសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ ដើម្បីស្នើសុំប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់។

<u>សំណួរ២៦</u>: ប្រជាពលរដ្ឋធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឃុំ សង្កាត់ផ្សេង ហើយបានផ្លាស់ទីលំនៅមករស់នៅក្នុងឃុំ សង្កាត់ថ្មី ហើយគាត់មានបំណងបោះឆ្នោតនៅ ឃុំ សង្កាត់ថ្មីនេះ តើគាត់ត្រូវធ្វើដូចម្តេច?

<u>ចម្លើយ:</u> ក្នុងករណីនេះគាត់ត្រូវទៅជួបក្រុមចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត ដោយយកទៅជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ/និងឯកសារបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការចុះឈ្មោះបោះឆ្នោត បង្ហាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងឯកសារភស្តុតាង ដែលបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ថ្មី ដូចជាសៀវភៅ គ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅដើម្បីស្នើសុំចុះឈ្មោះបោះឆ្នោត។

<u>សំណួរ២៧</u>: តើក្នុងករណីអ្វីខ្លះ ដែលក្រុមចុះឈ្មោះបោះឆ្នោតបដិសេធការសុំចុះឈ្មោះបោះឆ្នោត?

<u>ចម្លើយ:</u> ប្រធានក្រុមចុះឈ្មោះបោះឆ្នោតបដិសេធការសុំចុះឈ្មោះបោះឆ្នោតដូចមានករណីខាងក្រោម៖

- ប្រជាពលរដ្ឋគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការចុះឈ្មោះបោះឆ្នោត
- ប្រជាពលរដ្ឋមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប៉ុន្តែ ៖
  - មិនទាន់គ្រប់អាយុ ១៨ឆ្នាំ គិតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
  - អាសយដ្ឋានលំនៅឋានក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរផ្សេងពីអាសយដ្ឋានលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត។

<u>សំណួរ២៨</u>: តើរយៈពេលសរុបនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតចាប់ពីថ្ងៃណា ដល់ថ្ងៃណា?

<u>ចម្លើយ:</u> រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតត្រូវបាន គ.ជ.ប កំណត់ធ្វើចាប់ពីថ្ងៃទី០១ ខែតុលា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ រយៈពេលសរុបខាងលើនេះត្រូវគិតរួមបញ្ចូលទាំងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការប្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដំណើរការប្តឹងតវ៉ា ឬ/និង ប្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោតព្រមទាំងការផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការផង។

<u>សំណួរ២៩</u>: តើការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ ចាប់ផ្តើម និងបញ្ចប់ពីថ្ងៃណា ដល់ថ្ងៃណា?

<u>ចម្លើយ:</u> ការចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨ និងបញ្ចប់នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨។

<u>សំណួរ៣០</u>: តើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ឬស្មៀនឃុំ សង្កាត់ អាចធ្វើសាក្សីឱ្យប្រជាពលរដ្ឋដើម្បីស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបានដែរឬទេ ?

ចម្លើយ: ក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះឆ្នោតបោះឆ្នោតប្រចាំឆ្នាំ បានចែងថា «សាក្សីមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ជំទប់ ចៅសង្កាត់រង ឬស្មៀនឃុំ សង្កាត់»។

<u>សំណួរ៣១</u>: តើមានទោសដែរឬទេចំពោះជនណាដែលក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណ ឬលិខិតបញ្ជាក់អត្តសញ្ញាណ ឬលិខិតបញ្ជាក់ទីលំនៅពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត?

ចម្លើយ: មាត្រា ១៤១ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចែងថា «ត្រូវជាកពិន័យជាប្រាក់ពី ១,០០០,០០០ (មួយលាន)រៀល ទៅ ៥,០០០,០០០ (ប្រាំលាន)រៀល ដោយ គ.ជ.ប ដោយពុំទាន់គិតទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណាដែលក្លែងបន្លំឯកសារ បញ្ជាក់អត្ត-សញ្ញាណពាក់ព័ន្ធនឹងការបោះឆ្នោត។

ភ្នាក់ងារគណបក្សនយោបាយ

<u>សំណួរ៣២</u>: យ៉ាងដូចម្តេចដែលហៅថាភ្នាក់ងារគណបក្សនយោបាយ?

ចម្លើយ: ភ្នាក់ងារគណបក្សនយោបាយគឺជាតំណាងដែលតែងតាំងដោយគណបក្សនយោបាយ និងត្រូវបានអនុញ្ញាតដោយ កបយ.ស ដើម្បីសង្កេតមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ ភ្នាក់ងារគណបក្សនយោបាយគឺជាអ្នកសង្កេតការណ៍ដែលមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់។

<u>សំណួរ៣៣</u>: តើគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយមានសិទ្ធិចាត់តាំងភ្នាក់ងាររបស់ខ្លួនប៉ុន្មានរូប ដើម្បីចូលរួមសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ និងនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់?

ចម្លើយ: គណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយមានសិទ្ធិចាត់តាំងភ្នាក់ងារពេញសិទ្ធិរបស់ខ្លួន ០១ (មួយ) រូប និងភ្នាក់ងារបម្រុងយ៉ាងតិច ០១ (មួយ) រូប ដើម្បីសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ និងតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលបានកំណត់ដោយ គ.ជ.ប។

<u>សំណួរ៣៤</u>: តើសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ ប្រជាការពារ និងកម្លាំងប្រដាប់អាវុធអាចធ្វើជាភ្នាក់ងារគណបក្សនយោបាយបានដែរឬទេ?

ចម្លើយ: ផ្អែកតាមបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០១៨ បានបញ្ជាក់ថាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ ប្រជាការពារ និងកម្លាំងប្រដាប់អាវុធមិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្ស នយោបាយឡើយ។

<u>សំណួរ៣៥</u>: តើការដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ត្រូវធ្វើនៅកន្លែងណា និងប្រព្រឹត្តទៅនៅពេលណា?

ចម្លើយ: គណបក្សនយោបាយដែលមានបំណងចាត់តាំងភ្នាក់ងាររបស់ខ្លួន ដើម្បីសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រូវដាក់ពាក្យចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ០៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតរហូត ១០ (ដប់) ថ្ងៃមុនថ្ងៃបញ្ចប់ដំណើរការនេះ។

<u>សំណួរ៣៦</u>: តើគណបក្សនយោបាយមានសិទ្ធិផ្លាស់ប្តូរភ្នាក់ងាររបស់ខ្លួនបានដែរឬទេ?

ចម្លើយ: គណបក្សនយោបាយដែលបានទទួលស្គាល់ឱ្យចុះឈ្មោះភ្នាក់ងារដើម្បីពិនិត្យមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត មានសិទ្ធិផ្លាស់ប្តូរភ្នាក់ងាររបស់ខ្លួនរហូតដល់ម៉ោង ១៧:៣០ នាទីមួយថ្ងៃមុនថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់។

អ្នកសង្កេតការណ៍

<u>សំណួរ៣៧</u>: យ៉ាងដូចម្តេចដែលហៅថាអ្នកសង្កេតការណ៍ជាតិ?

ចម្លើយ: អ្នកសង្កេតការណ៍ជាតិ គឺជាជនជាតិខ្មែរ ឬជនបរទេសដែលជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានទទួលស្គាល់ និងអនុញ្ញាតដោយ គ.ជ.ប។

<u>សំណួរ៣៨</u>: យ៉ាងដូចម្តេចដែលហៅថាអ្នកសង្កេតការណ៍ជាតិចល័ត?

ចម្លើយ: អ្នកសង្កេតការណ៍ជាតិចល័តសំដៅលើមន្ត្រីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលសាមីអង្គភាពស្នើសុំ និងត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឲ្យសង្កេតមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

<u>សំណួរ៣៩</u>: យ៉ាងដូចម្តេចដែលហៅអ្នកសង្កេតការណ៍អន្តរជាតិ?

ចម្លើយ: អ្នកសង្កេតការណ៍អន្តរជាតិគឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានា។

<u>សំណួរ៤០</u>: តើកាលបរិច្ឆេទនៃការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិចាប់ផ្តើមនៅពេលណា បញ្ចប់នៅពេលណា និងនៅកន្លែងណា?

<u>ចម្លើយ:</u> ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិត្រូវធ្វើនៅ គ.ជ.ប។ ការទទួលពាក្យចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨។

<u>សំណួរ៤១</u>: តើកាលបរិច្ឆេទនៃការចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិចាប់ផ្តើមនៅពេលណា បញ្ចប់នៅពេលណា និងនៅកន្លែងណា?

<u>ចម្លើយ:</u> អ្នកសង្កេតការណ៍អន្តរជាតិដែលមានបំណងចូលរួមសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍អន្តរជាតិនៅ គ.ជ.ប ឬតាមរយៈអ៊ីម៉ែល necinfo@forum.org.kh ក្នុងរយៈពេលចាប់តាំងពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨។

<u>សំណួរ៤២</u>: ករណីប្រធានក្រុមចុះឈ្មោះបោះឆ្នោត បដិសេធការសុំចុះឈ្មោះបោះឆ្នោត តើនីតិវិធីនៃការដាក់ពាក្យបណ្តឹងយ៉ាងដូចម្តេច?

<u>ចម្លើយ:</u> នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតមានដូចខាងក្រោម៖

- សាមីខ្លួន ឬតំណាងមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៣ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត។
- ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ សម្រេចបដិសេធ សាមីខ្លួន ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេល៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ។
- សាមីខ្លួន ឬតំណាង ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងតវ៉ាទៅ ក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល៥ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ។

សូមបញ្ជាក់ថា:

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។



<u>សំណួរ៤៣</u>: តើទីកន្លែង និងកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតនៅពេលណា?

<u>ចម្លើយ</u>: ចាប់ផ្តើមបិទផ្សាយនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅសាលាឃុំ សង្កាត់ និងនៅទីតាំងណាមួយក្នុងឃុំ សង្កាត់។ ចាប់តាំងពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ ប្រជាពលរដ្ឋមានសិទ្ធិប្តឹងតវ៉ា ឬជំទាស់លើបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតទៅក្រុមប្រឹក្សា ឃុំ សង្កាត់ (ក្នុងរយៈពេល០៥ថ្ងៃ)។

<u>សំណួរ៤៤</u>: តើបញ្ជីឈ្មោះអ្នកដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោតមានអ្នកណាខ្លះ?

<u>ចម្លើយ</u>: ឈ្មោះអ្នកបោះឆ្នោតដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោតមាន ៖ អ្នកដែលទទួលមរណភាព អ្នកដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត អ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ដោយមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់។

<u>សំណួរ៤៥</u>: តើការប្តឹងជំទាស់ពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតមានន័យយ៉ាងដូចម្តេច?

<u>ចម្លើយ</u>: ពាក្យបណ្តឹងជំទាស់អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង៖

- ក្នុងករណីដែលជននោះមិនមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដោយសារ៖
  - មិនមានសញ្ជាតិខ្មែរ
  - មិនទាន់គ្រប់អាយុចុះឈ្មោះបោះឆ្នោត
  - មិនមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត
  - ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័ន មានសមត្ថកិច្ច។
- ក្នុងករណីដែលជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង។

<u>សំណួរ៤៦</u>: តើនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ទាក់ទងនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតយ៉ាងដូចម្តេចដែរ?

ចម្លើយ:



<u>សំណួរ៤៧</u>: តើកាលបរិច្ឆេទនៃការផ្តល់សុពលភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០១៨ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅពេលណា?

<u>ចម្លើយ:</u> កាលបរិច្ឆេទនៃការផ្តល់សុពលភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៨ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ (ថ្ងៃចុងក្រោយ)។